# **ធាតុផ្សំអត្តនោម័ត** ( *Mens Rea* )

១. ជាទូទៅ អ្នកសិក្សាច្បាប់ព្រហ្មទណ្ឌ ដឹងថា មានធាតុផ្សំនៃបទល្មើសយ៉ាងតិចចំនួនពីរ៖ ធាតុផ្សំសម្ភារៈ http://www.measboralaws.com/detail/1050 និងធាតុផ្សំអត្តនោម័ត (*mens rea*)។ អ្នកស្រាវជ្រាវ មានការយល់ដឹងច្រើន អំពីធាតុផ្សំទីមួយ ក៏ប៉ុន្តែ មានការលំបាកយល់អំពីធាតុផ្សំទី២ ដែលមានលក្ខណៈអរូបិយ និងមានពាក្យជាច្រើនត្រូវបានប្រើប្រាស់ បង្ហាញពីធាតុផ្សំនេះ។

២. ការវិនិច្ឆ័យសេចក្តីលើបទល្មើសព្រហ្មទណ្ឌ ឈានទៅដល់ការប្រកាសពិរុទ្ធភាព និងការដាក់ទោសលើជនល្មើស ជាទូទៅ ទាមទារនូវការបង្ហាញធាតុផ្សំអត្តនោម័ត ឬនិយាយសាមញ្ញចិត្តទុច្ចរិត (guilty mind) លើកលែង បទល្មើសមួយចំនួន ដែលទាមទារធាតុផ្សំសម្ភារៈតែប៉ុណ្ណោះ (Strict Liability Offense) http://www.measboralaws.com/detail/1048 ដូចជាក្នុងវិស័យចរាចរណ៍ផ្លូវគោក ។

៣. មានវាក្យស័ព្ទច្បាប់ជាច្រើន ដែលឆ្លុះបញ្ចាំង អំពីធាតុផ្សំអត្តនោម័ត ដូចជា ចេតនា ការដឹង (knowledge) មានគោលបំណង (purpose) ធ្វេសប្រហែស (negligence) មិនប្រុងប្រយ័ត្ន (recklessness) ចេតនាទុច្ចរិត (malice) ជាដើម។ ពាក្យទាំងនេះ មានខ្លឹមសារមិនច្បាស់ទេ ហើយយុត្តាធិការខ្លះ ក៏មិនចាត់ពាក្យខ្លះ បង្ហាញពីធាតុផ្សំនេះផងដែរ។ ជាក់ស្តែង ពាក្យ “Recklessness” មិនត្រូវបានប្រើទេ។ ច្បាប់ឬយុត្តិសាស្ត្របរទេសខ្លះ ផ្តល់កម្រិតនៃធាតុផ្សំអត្តនោម័តមួយទាបជាងមួយ។ ចេតនា មានកម្រិតខ្ពស់ជាង recklessness។ យុត្តាធិការទាំងអស់ ឯកភាពថា ចេតនា គឺជាធាតុផ្សំអត្តនោម័ត។ ការបែងចែក ឬ ដាក់កម្រិតលំដាប់ថ្នាក់ពិតជាសំខាន់ ពីព្រោះបទល្មើសខ្លះទាមទារនូវប្រភេទនៃធាតុផ្សំអត្តនោម័តខុសគ្នា ហើយព្រះរាជអាជ្ញា ត្រូវបង្ហាញធាតុផ្សំនេះ។ បន្ថែមពីលើនេះ កម្រិតធាតុផ្សំអត្តនោម័ត ពាក់ព័ន្ធជាមួយនឹងការកំណត់ទោស។ ជាក់ស្តែង ចេតនាផ្ទាល់ អាចនាំឲ្យមានទោសធ្ងន់ក៏អាចថាបាន ដោយមិនគិតពីភាពងាយស្រួលក្នុងការបង្ហា ញធាតុផ្សំនេះ។

៤. ចេតនា ត្រូវបានផ្តល់ន័យថា ការចង់បានអ្វីដូចដែលជនល្មើសប៉ង។ ជនល្មើស ដឹងថាបេះដូង ជាសរីរាង្គសំខាន់ បានលើកកាំភ្លើងបាញ់ចំបេះដូងជនរងគ្រោះ ជនរងគ្រោះបានស្លាប់។ នេះជាឧទាហរណ៍ដ៏សាមញ្ញមួយ អំពីអ្វីទៅជាចេតនា។ ចេតនានេះ ជាចេតនាផ្ទាល់ (direct intent)។ ជនម្នាក់បានចោលដុំថ្មបំបែកកញ្ចក់បង្អួច ចេតនាដើម្បីឲ្យកញ្ចក់ធ្លាក់ត្រូវក្បាលមនុស្សនៅខាងក្រោម។ នេះជាចេតនាដោយប្រយោល (indirect intent)។ វាស្រដៀងគ្នានឹង ចេតនាមានលក្ខខណ្ឌ (conditional intent) ដែលអះអាងដោយយុត្តាធិការអាឡឺម៉ង់។ មានផងដែរនូវចេតនាជាមុន (aforethought intent)។ ជាទូទៅ ចេតនា ត្រូវកើតឡើងព្រមគ្នានឹងសកម្មភាព ប្រសិនមិនដូចនេះទេ វាអាចមិនមែន ជាបទល្មើសដូចដែលបានចោទឡើង។ ចេតនានេះទៀត ត្រូវបានបែកចែកជាទូទៅ (general intent) និងជាក់លាក់ (specific intent)។ ចេតនាទូទៅ មានធាតុផ្សំចង់ (desire) និង បានដឹង (aware)។ បទរំលោភសេពសន្ថវៈ ទាមទារតែចេតនាទូទៅ។ ជនល្មើសចង់បំពេញចំណង់ផ្លូវកាម និងដឹងថាការរំលោភសេពសន្ថវៈខុសច្បាប់ តែគាត់នៅតែប្រព្រឹត្ត។ ចេតនាពិសេស គឺហួសពីចេតនាទូទៅ ព្រោះ

ទាមទារឲ្យសម្រេចបំណងអ្វីមួយជាក់លាក់។ នេះករណីបទលួចទ្រព្យ ជនល្មើស ចង់បានទ្រព្យ យកមកជារបស់ខ្លួន។ បទប្រល័យពូជសាសន៍ តម្រូវឲ្យមានចេតនាជាក់លាក់។

៥. ចេតនាអាចត្រូវបានផ្ទេរ (transfer of malice) ឬអាចត្រូវបានសន្មត់ (constructive *mens rea*)។ ទី១. អនុវត្តចំពោះការសម្លាប់មនុស្ស ខុសពីគោលដៅ។ ជនល្មើស ចង់សម្លាប់ *ក* តែបែរជាបាញ់សម្លាប់ *ខ*។ នេះជាការផ្ទេរចេតនា សម្លាប់ *ក* ទៅ ជាចេតនាសម្លាប់ *ខ*។ ទីពីរកើតមានក្នុងបទល្មើស នៃប្រទេសកុំមុនឡ គឺ Felony-Murder (សម្លាប់នារីរងគ្រោះក្នុងអំឡុងពេលរំលោភសេពសន្ថវៈ)។ ចេតនា របស់ជនល្មើស គឺ រំលោភសេពសន្ថវៈ។ តាមទ្រឹស្តីនេះ ចេតនា រំលោភ នាំឲ្យសន្និដ្ឋាន ថា មានចេតនាសម្លាប់។ វាជារឿងចម្រូងចម្រាស់ អាស្រ័យហេតុនេះ ប្រទេសខ្លះមិនប្រកាន់យកទៀតទេ។

៦. ពាក្យ "មូលហេតុ Motive" និង"ចេតនា" មិនដូចគ្នាទេ។ Motive នាំឲ្យមានចេតនា ហើយការសំអាងលើ Motive មិនអាចរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌទេ។ ឧទាហរណ៍ គ្រូពេទ្យ តាមសំណើរបស់អ្នកជំងឺរាំរ៉ៃ ដោយមូលហេតុអាណិត បានចាក់ថ្នាំសម្លាប់អ្នកជំងឺ។ គ្រូពេទ្យ នៅតែមានចេតនា សម្លាប់ដែលនាំឲ្យមានការទទួលខុសត្រូវព្រហ្មទណ្ឌ ក្នុងបទណាមួយ ជាមួយនឹងស្ថានសម្រាលអនុលោមតាមច្បាប់នៃប្រទេសនីមួយៗ។

៧. Recklessness៖មានទង្វើជាច្រើនបង្កផលវិបាកដល់សង្គមដែលច្បាប់ត្រូវចាត់វិធានការដើម្បីការពារសុវត្ថិភាព ឬសន្តិសុខរបស់ប្រជាពលរដ្ឋ តាមរយៈចែងជាបទល្មើសជាមួយធាតុផ្សំអត្តនោម័ត (ចេតនា) ឬ ការធ្វេសប្រហែស។ ក្នុងករណីខ្លះ ធាតុផ្សំមិនមានចែង ដូចនេះ Recklessness ត្រូវបានយោង ឬប្រើប្រាស់ដើម្បីបំពេញចំណុចខ្វះខាត។ វាបង្ហាញតាមរយៈសកម្មភាព ដែលបង្កហានីភ័យ ដោយជនល្មើសបានដឹងក៏ប៉ុន្តែមិនខ្វល់ និងនៅតែធ្វើសកម្មភាព។ នេះបង្ហាញពី ចិត្តទុច្ចរិត (guilty mind)។ ឧទាហរណ៍ នៅក្នុងវង្គសាលមួយមានមនុស្សជាច្រើនដែលកំពុងរាំច្រៀង ជនល្មើសបានយកកាំភ្លើងបាញ់តាមបង្អួចកញ្ចក់ចូលទៅក្នុងបន្ទប់វង្គសាលដែលមានមនុស្សអ៊ូអរ។ នេះបង្ហាញពីនូវហានីភ័យខ្ពស់ ហើយជនល្មើសមិនខ្វល់អំពីអ្វីកើតឡើងឡើយ។ ផ្អែកលើឧទារហណ៍ អ្នកស្រាវជ្រាវខ្លះ បានអះអាងថា Recklessness ស្រដៀង ឬប្រហែលកម្រិតចេតនា។ Recklessness ស្មើនឹងការធ្វេសប្រហែសដ៏ធ្ងន់ធ្ងរ (gross negligence)។ យុត្តាធិការប្រទេសខ្លះ ឲ្យកម្រិត Recklessness ទាបជាងការធ្វេសប្រហែល។ ក៏ប៉ុន្តែ ប្រសិនគេទទួលយកឧទាហរណ៍ក្នុងកថាខ័ណ្ឌទី៧ ខាងលើ ត្រឹមត្រូវឆ្លុះនឹងធាតុអត្តនោម័ត Recklessness អ្នកនិពន្ធអត្ថបទនេះ ឯកភាពថា Recklessness ខ្ពស់ជាង ការធ្វេសប្រហែស។

៨.ការធ្វេសប្រហែស ខុសពីចេតនាមិនផ្ទាល់ដែលបរិយាយខាងលើ។ វាមានប្រភពពីវិស័យរដ្ឋប្បវេណី ពោលគឺ ករទទួលខុសត្រូវចំពោះអំពើអនីត្យានុកូល (tort) ដោយសារការធ្វេសប្រហែស http://www.measboralaws.com/detail/740 ។ ទោះបីជាយ៉ាងនេះក្តី ក្នុងការទទួលខុសត្រូវព្រហ្មទណ្ឌកម្រិត ផ្ទធ្ងរនៃទង្វើត្រូវខ្ពស់ជាងសម្រាប់ការទទួលខុសត្រូវខាងរដ្ឋប្បវេណី។ ផ្អែកតាមមូលដ្ឋាននេះហើយ ទើបរដ្ឋភាគច្រើន ការធ្វេសប្រហែសក្នុងបទព្រហ្មទណ្ឌ ទាមទារហួសពីការធ្វេសប្រហែសធម្មតា

(mere negligence)។ យុត្តិសាស្ត្រអាឡឺម៉ង់ បានប្រើពាក្យ "ការធ្វេសប្រហែសដោយសម្បជញ្ញៈ" (conscious negligence)។

៩. អ្វីខុសគ្នារវាង Recklessness និង ការធ្វេសប្រហែស គឺថាក្នុងករណី Recklessness ជនល្មើសដឹងច្បាស់ថាមានហានិភ័យ។ ចំណែក ការធ្វេសប្រហែស ជនល្មើសមិនដឹងច្បាស់អំពីហានិភ័យទេ។ ជាមួយគ្នានេះដែរ សូមកុំច្រឡំរវាងការធ្វេសប្រហែស និង ខកខាន ឬអំពើអកម្ម (omission) ដែលគេរាប់បញ្ចូលក្នុងធាតុផ្សំសម្ភារៈ ។ ការខកខាន ជាបទល្មើសព្រហ្មទណ្ឌ ឬជាផ្នែកនៃធាតុផ្សំសម្ភារៈ។ ការធ្វេសប្រហែលជាធាតុផ្សំអត្តនោម័ត ។

១០.ដោយសារ ការធ្វេសប្រហែស មានប្រភពពីអំពើអនីត្យានុកូល (Tort) គេត្រូវកំណត់ជាមុនសិនថា តើអ្នកប្រព្រឹត្ត មានករណីកិច្ចប្រុងប្រយ័ត្ន ( Duty of Care) លើជនរងគ្រោះឬទេ។[1] ជនល្មើសបានបំពាន ករណីកិច្ចនោះ ហើយធ្វើឲ្យជនរងគ្រោះ មានហានីយភ័យ។ ហានីយភ័យ ត្រូវតែខ្ពស់ (great short of reasonable standard)។[2] ប្រទេសខ្លះ បានចែងអំពី បទសម្លាប់មនុស្សដោយការធ្វេសប្រហែសធ្ងន់ធ្ងរ (gross negligent manslaughter) ដូចជា ការបើកបរធ្វេសប្រហែស នាំឲ្យមនុស្សស្លាប់។ វេជ្ជបណ្ឌិត មានករណីកិច្ចពិនិត្យ និងថែទាំ ព្យាបាលអ្នកជំងឺ ប្រសិនបើគាត់ទុកអ្នកជំងឺចោលដោយមិនពិនិត្យ ថែទាំង និងព្យាបាល នោះនឹងនាំឲ្យអ្នកជំងឺស្លាប់។ គាត់អាចត្រូវបានចោទពីបទសម្លាប់មនុស្សដោយការធ្វេសប្រហែស។ ពាក់ព័ន្ធនឹងការព្យាបាល គ្រូពេទ្យត្រូវអនុវត្តតាមស្តង់ដាប្រតិបត្តិ X ក៏ប៉ុន្តែគ្រូពេទ្យមិនបានបំពេញតាមទេ ឬធ្វើទាបជាងស្តង់ដា នាំឲ្យអ្នកជំងឺស្លាប់។

១១. ដើម្បីបង្ហាញនូវ ការធ្វេសប្រហែស យុត្តិសាស្ត្រ បានប្រកាន់យកនូវវិធីសាស្ត្រ មនុស្សមានហេតុផល (reasonable person) ដែលជាវិធីសាស្ត្រសត្យានុម័ត (objective test)។ ក្នុងស្ថានភាពស្រដៀងគ្នានឹងអ្វីដែលជនល្មើសកំពុងប្រឈម តើមនុស្សមានហេតុផល ត្រូវឆ្លើយតបយ៉ាងម៉េច?។ ស្តង់ដានេះមិនសុក្រឹត្យពេកទេ ដូចនេះត្រូវពិចារណានូវកត្តាដទៃទៀត ដូចជា អាយុ ស្ថានភាពសុខភាព ឬបរិស្ថានជុំវិញ របស់ជនល្មើស។ ឧទាហរណ៍ ក្នុងករណី ក្មេងលេងភ្លើង បង្កឲ្យឆេះផ្ទះគេ។ ស្តង់ដាមនុស្សមានហេតុផល មិនអាចត្រូវបានអនុវត្តទេ ដោយសារក្មេងមានការយល់ដឹង ឬ មិនសូវមានហេតុផលទេ។ ធាតុផ្សំខ្លះត្រូវបានពិចារណា ដោយអត្តនោម័ត ( subjective)។

<u>**កំណត់សំគាល់**</u>៖ មាត្រា ៤ នៃក្រមព្រហ្មទណ្ឌកម្ពុជា ឆ្នាំ ២០០៩ ស្តីពី ចេតនាប្រព្រឹត្តបទល្មើសបានចែង៖ *ពុំមានបទល្មើសទេ ប្រសិនបើគ្មានចេតនាប្រព្រឹត្ត ។ ប៉ុន្តែក្នុងករណីដែលច្បាប់បានចែងទុកមុន បទល្មើសមួយអាចកើតចេញពីការមិនប្រុងប្រយ័ត្ន <u>ការខ្ជីខ្ជា</u> ការ<u>ធ្វេសប្រហែស</u> ឬការមិន<u>គោរពកាតព្វកិច្ច</u>ដោយខ្សែកណាមួយ* ។ មាត្រា ២៩ ប្រើពាក្យ "<u>ចេតនា"</u> ដល់ការប៉ុនប៉ង ឬការសម្រេចបទល្មើស (អ្នកសមគំនិត)។ មាត្រា ១៩៣ ស្តីពី ទារុណកម្ម ក្នុងបទឧក្រិដ្ឋកម្មសង្គ្រាម ប្រើពាក្យ "ចេតនានូវការឈឺចាប់"។ បទមនុស្សឃាត មាត្រា ១៩៩ ប្រើពាក្យ "សម្លាប់ដោយចេតនា"។ មាត្រា ៧៩

ប្រើពាក្យ ការប្រើប្រាស់កូនសោដែលបានមក“ដោយឧបាយកលទុច្ចរិត”។ មាត្រា ១៨៣ ស្តីពី បទប្រល័យពូជសាសន៍ ប្រើពាក្យ “ក្នុងគោលបំណងបំផ្លាញទាំងមូល” និង “សំដៅរារាំងកំណើតទារកក្នុងក្រុម”។ រីឯ មាត្រា ៣៣០ (មាត្រា ៣៣០ បទញុះញង់ឲ្យបោះបង់ទារក) ប្រើឃ្លា “ក្នុងគោលដៅចង់បានកម្រៃ” និងជាចុងក្រោយមាត្រា ៣៨៤ ស្តីពីបទបន្លំ បានប្រើពាក្យ “ដឹងថាខ្លួនគ្មានលទ្ធភាពដាច់ខាតនឹងបង់ថ្លៃ”។ តាមខ្លឹមសារខាងលើ ក្រៅពីចេតនា ធាតុអត្តនោម័ត ត្រូវបានឆ្លុះដោយពាក្យ “មិនប្រុងប្រយ័ត្ន” “ខ្ជីខ្ជា” “ការធ្វេសប្រហែស” ឬ“ការមិនគោរពកាតព្វកិច្ច” ក្នុងករណីច្បាប់ចែងជាមុន។ តាមរយៈនេះ មានបទល្មើសតិចតួចណាស់បង្ហាញពីធាតុផ្សំអត្តនោម័តដែលនាំឲ្យមេធាវី ចៅក្រម ព្រះរាជអាជ្ញា ត្រូវពិចារណាច្បាប់ ឬយុត្តិសាស្ត្រដទៃ ដើម្បីបញ្ជាក់ថា ធាតុផ្សំអត្តនោម័តនៃបទល្មើសនេះជាអ្វី។ មាត្រាដកស្រង់ខាងលើ ភាគីច្រើនប្រើពាក្យ ចេតនា គោលបំណង (សំដៅ ឬគោលដៅ) និងចុងក្រោយ គឺការដឹង។ ករណីនេះ ប្រសិនបើជនល្មើស បានដឹងតែនៅប្រព្រឹត្ត នោះពិតជាបំពេញបានធាតុផ្សំអត្តនោម័តហើយ។

**ឯកសារយោង៖** **1**. Catherine Elliott, French Criminal Law, 2001, pp.64-83; **2**. Catherine Elliott and Frances Quinn, Criminal Law, 6th ed., 2006, pp.16-30; **3**. Antonio Cassese, the Oxford Companion to the International Criminal Justice, 2009, pp. 288, 302, 376, 426, 433, 479 and 517; **4**. Michael Bohlander, Principle of German Criminal Law, 2009, pp.59-76; **5**. Kevin Jon Heller and Markus D. Dbber, the Handbook of Comparative Criminal Law, *France* by Catherine Elliott, 2011, p. 216-220; **6**. Vivenne O’Connor and Colette Rausch, Model Codes for Post-Conflict Criminal Justice, Model Criminal Code, 2007, pp. 66-72។